# ជំនួយផ្នែកហិរញ្ញវត្ថុ នៅ PeaceHealth

## ជំនួយអាចរកបាន

PeaceHealth ប្តេជ្ញាធានាថាអ្នកជំងឺរបស់យើងទទួលបានការថែទាំដែលពួកគេត្រូវការ មិនថាពួកគេមានលទ្ធភាពបង់ប្រាក់បានឬអត់នោះទេ។ ការផ្តល់ការថែទាំសុខភាពដល់អ្នកដែលមិនអាចមានលទ្ធភាពក្នុងការបង់ប្រាក់គឺជាផ្នែកមួយនៃបេសកកម្មរបស់យើង។ ច្បាប់តម្រូវឱ្យមន្ទីរពេទ្យរបស់យើងផ្តល់ការថែទាំដែលមានការបញ្ចុះតម្លៃដល់អ្នកជំងឺដែលមានសិទ្ធិទទួល។ អ្នកអាចមានលក្ខណសម្បត្តិគ្រប់គ្រាន់សម្រាប់ការថែទាំដែលមានការបញ្ចុះតម្លៃដោយផ្អែកលើទំហំគ្រួសារ និងប្រាក់ចំណូលរបស់អ្នក ទោះបីជាអ្នកមាន ធានារ៉ាប់រងសុខភាពក៏ដោយ។ អ្នកជំងឺដែលមានបញ្ហាក្នុងការទូទាត់វិក្កយបត្រគួរតែទូរសព្ទទៅអ្នកឯកទេសគណនីអ្នកជំងឺតាមលេខដែលបានរាយខាងក្រោម។

## របៀបដាក់ពាក្យសុំ

ដោយផ្ទាល់ តាមប្រៃសណីយ៍ ឬតាមទូរសព្ទ។ អ្នកជំងឺអាចដាក់ពាក្យសុំជំនួយផ្នែកហិរញ្ញវត្ថុតាមរយៈការដាក់ស្នើពាក្យសុំ និងការផ្តល់ឯកសារគាំទ្រ។ ប្រសិនបើមានសំណួរ សូមទាក់ទងមកយើងខ្ញុំ ឬដើម្បីស្នើសុំច្បាប់ចម្លងនៃបែបបទពាក្យស្នើសុំ និងគោលការណ៍របស់យើងដោយឥតគិតថ្លៃ។

- **តាមទូរសព្ទ៖**
    - 877-202-3597 ផ្នែកជំនួយភាសាអង់គ្លេស
    - 844-746-4737 ភាសាផ្សេងទៀតទាំងអស់ [Para español o tagalog, 国语, для русского языка, cho Việt]
- **គេហទំព័រ PeaceHealth៖** peacehealth.org/financialassistance
- ដោយផ្ទាល់៖ មជ្ឈមណ្ឌលវេជ្ជសាស្ត្រ PeaceHealth
- **ដើម្បីទទួលបានឯកសារតាមរយៈប្រៃសណីយ៍ដោយឥតគិតថ្លៃ៖** សូមហៅទូរសព្ទមកយើងខ្ញុំតាមលេខដែលបានរាយខាងលើ។

## ព័ត៌មានសង្ខេបអំពីជំនួយហិរញ្ញវត្ថុ

**សេវាព្យាបាលបន្ទាន់៖** បន្ទប់សង្គ្រោះបន្ទាន់នៅមន្ទីរពេទ្យទាំងអស់របស់យើងអនុវត្តតាមបទបញ្ញត្តិនៃច្បាប់ស្តីពីការព្យាបាលជំងឺសង្គ្រោះបន្ទាន់ និងច្បាប់ការងារ (Emergency Medical Treatment and Labor Act, EMTALA)។ យើងខ្ញុំថែទាំអ្នកជំងឺដែលមានតម្រូវការជំងឺសង្គ្រោះបន្ទាន់ មិនថាអ្នកជំងឺមានធានារ៉ាប់រងឬអត់នោះទេ ដោយមិនតម្រូវឱ្យមានការបង់ប្រាក់នៅពេលផ្តល់សេវាឡើយ។ ជំនួយផ្នែកហិរញ្ញវត្ថុអាចរកបានបើចាំបាច់សម្រាប់ការសង្គ្រោះបន្ទាន់។

**តើខ្ញុំគួរធ្វើដូចម្តេច ប្រសិនបើខ្ញុំមិនអាចទូទាត់វិក្កយបត្របាន?** រាល់អ្នកជំងឺអាចដាក់ពាក្យសុំជំនួយផ្នែកហិរញ្ញវត្ថុបាន។ អ្នកណាដែលដាក់ពាក្យស្នើសុំ នឹងត្រូវបានស្នើសុំឱ្យផ្តល់ព័ត៌មានដែលបង្ហាញពីតម្រូវការផ្នែកហិរញ្ញវត្ថុរបស់ពួកគេ។ PeaceHealth ផ្តល់ជំនួយក្នុងការទូទាត់វិក្កយបត្រដោយផ្អែកលើប្រាក់ចំណូល និងសមត្ថភាពក្នុងការទូទាត់របស់អ្នក។ យើងមានការបញ្ចុះតម្លៃចន្លោះពី 70% ទៅ 100%។ ចំនួនទឹកប្រាក់ដែលអាចទ្រទ្រង់បានអាស្រ័យលើតម្រូវការផ្នែកហិរញ្ញវត្ថុរបស់អ្នកជំងឺ។

**តើអ្វីខ្លះដែលត្រូវបានរ៉ាប់រង?** អ្នកជំងឺដែលត្រូវបានអនុម័តសម្រាប់ជំនួយផ្នែកហិរញ្ញវត្ថុនឹងត្រូវបានរ៉ាប់រងលើការសង្គ្រោះបន្ទាន់ ឬការព្យាបាលចាំបាច់ផ្នែកវេជ្ជសាស្ត្រ ហើយនឹងមិនត្រូវបានគិតថ្លៃលើសពីចំនួនទឹកប្រាក់ដែលត្រូវបានគិតប្រាក់ជាទូទៅ (AGB) ដល់អ្នកជំងឺដែលមានធានារ៉ាប់រងនោះទេ។

**តើខ្ញុំអាចធ្វើការទូទាត់ប្រាក់បានទេ?** PeaceHealth ស្នើសុំការទូទាត់ពេញលេញនៅពេលអ្នកទទួលបានរបាយការណ៍វិក្កយបត្រដំបូងរបស់អ្នក។ អ្នកអាចបង់ប្រាក់សមតុល្យរបស់អ្នកបានដោយវិធីជាច្រើន ដូចជា៖ កាតឥណទាន កាតបង់ប្រាក់ជាមុន សាច់ប្រាក់ សែក, ឬការទូទាត់តាមអ៊ីនធឺណិត។ ផែនការទូទាត់ក៏មានផ្តល់ជូនដែរ។ សូមហៅទូរសព្ទទៅលេខខាងលើដើម្បីពិភាក្សាអំពីជម្រើសនៃការទូទាត់ជាមួយអ្នកឯកទេសគណនីអ្នកជំងឺ។

**ជំនួយផ្នែកធានារ៉ាប់រង៖** យើងអាចជួយអ្នកជំងឺដាក់ពាក្យសុំកម្មវិធីរបស់សហគមន៍ ឬរដ្ឋាភិបាលដែលអាចជួយចេញថ្លៃលើវិក្កយបត្រពេទ្យបាន។ អ្នកជំងឺដែលមិនមានធានារ៉ាប់រងអាចទាក់ទងមកយើងខ្ញុំដើម្បីសុំជំនួយ។ យើងខ្ញុំនឹងជួយអ្នកជំងឺដែលមានវិក្កយបត្រច្រើន ទោះបីជាធានារ៉ាប់រងបានបង់រួចហើយក៏ដោយ។

**ប្រសិនបើភាសាអង់គ្លេសមិនមែនជាភាសាទីមួយរបស់អ្នក៖** គោលការណ៍ជំនួយផ្នែកហិរញ្ញវត្ថុរបស់យើង ពាក្យស្នើសុំ និងសេចក្តីសង្ខេបនេះមានជាភាសាដូចខាងក្រោម៖

- ភាសាអេស្ប៉ាញ (Español)
- ភាសាចិន (中文)
- ភាសាសូម៉ាលី (Soomaalida)
- ភាសាអ៊ុយក្រែន (Українська)
- ភាសាអាល្លឺម៉ង់ (Deutsch)
- ភាសាអារ៉ាប់ (العربية)
- ភាសាខ្មែរ
- ភាសាជប៉ុន (日本語)
- ភាសាថៃ (ไทย)
- ភាសាតាកាឡុក
- ភាសាកូរ៉េ (한국어)
- ភាសារ៉ូម៉ានី (Română)
- ភាសាហ្វាស៊ី
- ភាសាពុនចាប៊ី
- ភាសាវៀតណាម (Tiếng Việt)
- ភាសារុស្ស៊ី (Русский)
- ភាសាជូគី
- ភាសាអូរ៉ូម៉ូ
- ភាសាបារាំង (Français)

PeaceHealth